# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ:** ១៧០៩ សជណ

រាជធានីភ្នំពេញថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សូមគោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការដែលជាប្រធានក្រសួង ស្ថាប័ន**

**កម្មវត្ថុ** : គោលការណ៍ប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា និងពលករអណ្តែតរបស់ក្រសួង ស្ថាប័នសម្រាប់ឆ្នាំ២០១០ ។

**យោង** : ចំណាឯកភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១០ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការដែលជាប្រធានក្រសួង ស្ថាប័នមេត្តាជ្រាបថា រាជរដ្ឋាភិបាលបានសម្រេចជាគោលការណ៍លើការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា និងពលករអណ្តែតនៅតាមក្រសួង ស្ថាប័នសម្រាប់ឆ្នាំ២០១១ ដូចខាងក្រោម:

១- គ្រប់ក្រសួង ស្ថាប័ន ក្រៅពីក្រសួងបរិស្ថាន ត្រូវបន្តប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា និងពលករអណ្តែតក្នុងចំនួនដូចកំពុងអនុវត្តក្នុងពេលបច្ចុប្បន្ននេះ ។ ក្នុងករណីចាំបាច់ ត្រូវពិនិត្យលទ្ធភាពបង្កើនចំនួនបន្ថែម ប៉ុន្តែមិនឲ្យលើសពីចំនួន១៥ % នៃតួលេខប្រើបាស់បច្ចុប្បន្ន ដោយតម្រូវឲ្យពិនិត្យ និងវាយតម្លៃទៅលើទំហំ មុខងារ និងគោលដៅនៃការប្រើប្រាស់ឲ្យបានច្បាស់លាស់ ។

២- ឯកភាពឲ្យក្រសួងបរិស្ថានធ្វើការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាបន្ថែមចំនួន ៤៨០ នាក់ សម្រាប់ប្រើប្រាស់ជាឧទ្យានុរក្សតាមគោលដៅនៃតំបន់ឧទ្យានជាតិនានា ។

អាស្រ័យហេតុនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការដែលជាប្រធានក្រសួង ស្ថាប័ន មេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ ។

សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការដែលជាប្រធានក្រសួង ស្ថាប័ន ទទួលនូវការគោរពរាប់អានដោយស្មោះ អំពីខ្ញុំ ។

**ឧបនាយករដ្ឋមន្ត្រី**

**សុខ អាន**

**ចម្លងជូន** :
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ឯកសារ-កាលប្បវត្តិ